វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១៦ ខែ វិច្ឆិកា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការអភិវឌ្ឍប្រេងកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅមុខ
- ការដកចេញប្រព័ន្ធអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុបនឹងមិនប៉ះពាល់ដល់គម្រោងអភិវឌ្ឍន៍ទេ
- អាមេរិកផ្អាកជាបណ្តោះអាសន្នលើការយកពន្ធនាំចូលរថយន្តដែលលោកត្រាំបានដាក់

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការអភិវឌ្ឍប្រេងកំពុងធ្វើដំណើរឆ្ពោះទៅមុខ

កិច្ចសន្យាសម្រាប់ការកែលម្អ និងលើកកម្ពស់ឧបករណ៍ផលិតប្រេងក្នុងការអភិវឌ្ឍប្រេងអប្សរាកម្ពុជាបានផ្តល់ឱ្យក្រុមហ៊ុន Keppel Shipyard Ltd ក្នុងតម្លៃ ២១,៧ លានដុល្លារអាមេរិក។ កិច្ចសន្យានេះត្រូវបានប្រគល់ជូនដោយក្រុមហ៊ុន KrisEnergy ដែលជាក្រុមហ៊ុនមានភាគហ៊ុន៩៥% នៃអណ្តូងប្រេងអប្សរាក្នុងប្លុកA (ក្រៅពីនេះជាភាគហ៊ុនរបស់រដ្ឋាភិបាលកម្ពុជា)។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រុមហ៊ុន KrisEnergy នៅកាសែតភ្នំពេញប៉ុស្តិ៍បានឱ្យដឹងថា ឧបករណ៍ផលិតប្រេងដែលកែលម្អរួច អាចផលិតបាន៣០ 000 បារ៉ែលក្នុងមួយថ្ងៃ ហើយនឹងត្រូវបានបំពាក់ដោយឧបករណ៍បំបែកឧស្ម័ន ប្រេង និងទឹក។

ឯកឧត្តម ជៀប សួរ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងឥន្ធនៈនៅក្រសួងរ៉ែនិងថាមពល បានស្វាគមន៍ចំពោះព័ត៌មាននេះ ដោយថ្លែងថា «កិច្ចព្រមព្រៀងនេះគឺជាជំហានដ៏ល្អសម្រាប់ការទាញយកប្រេងរបស់កម្ពុជា»។ លោកបានបង្ហាញពីភាពសុទិដ្ឋិនិយមថា ការទាញយកប្រេងដំបូងរបស់កម្ពុជានឹងដំណើរការនៅត្រឹមចុងឆ្នាំ២០១៩។

### តារាងប្រចាំសប្តាហ៍៖ អត្រាកំណើននៅក្នុងវិស័យឧស្សាហកម្ម

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីកំណើននៃវិស័យឧស្សាហកម្មរបស់ប្រទេសកម្ពុជាពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩ រួមទាំងកំណើននៃអនុវិស័យនេះ។ វិស័យឧស្សាហកម្មបានកើនឡើងជាបន្តបន្ទាប់ប្រហែល១០%ជាមធ្យម។

វិស័យអចលនទ្រព្យបានកើនឡើង១៨% ក្នុងអំឡុងពេលដូចគ្នា ដែលជាចលករសំខាន់បំផុតនៃកំណើនឧស្សាហកម្មទាំងមូល។ ឧស្សាហកម្មវាយនភណ្ឌ មានកំណើនតិចជាងគេក្នុងអំឡុងពេលដូចគ្នា ពោលគឺ៧%ក្នុងមួយឆ្នាំគិតជាមធ្យម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរំពឹងថា វិស័យនីមួយៗនៅក្នុងឆ្នាំ២០១៩ នឹងមានអត្រាកំណើនប្រហាក់ប្រហែលទៅនឹងឆ្នាំ២០១៧។

**អត្រាកំណើនឧស្សាហកម្មឆ្នាំ២០១៣ដល់ឆ្នាំ២០១៩**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការដកចេញនូវប្រព័ន្ធអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុបនឹងមិនប៉ះពាល់ដល់គម្រោងអភិវឌ្ឍន៍ទេ

ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា បានមានប្រសាសន៍ទៅកាន់អ្នកយកព័ត៌មានថា គម្រោងអភិវឌ្ឍន៍នឹងមិនរងផលប៉ះពាល់ទេ នៅអំឡុងពេលសហភាពអឺរ៉ុបពិនិត្យឡើងវិញនូវប្រព័ន្ធអនុគ្រោះពន្ធ(EBA)សម្រាប់ការនាំចេញរបស់កម្ពុជា។

ឯកអគ្គរដ្ឋទូតបានលើកឡើងថា សហភាពអឺរ៉ុបនៅតែបន្តប្តេជ្ញាចិត្តគាំទ្រចំពោះកម្មវិធីអភិវឌ្ឍន៍រយៈពេលវែងនៅកម្ពុជា និងយល់ថាកម្មវិធីអភិវឌ្ឍន៍ និងបញ្ហាពាណិជ្ជកម្មជាបញ្ហាពីរដាច់ដោយឡែក។

ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុបបានប្រាប់កម្ពុជាកាលពីខែតុលាថា សហភាពអឺរ៉ុបបានចាប់ផ្តើមដំណើរការដកប្រព័ន្ធអនុគ្រោះពន្ធ(EBA) ដោយសារកង្វល់នៃការថយចុះការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

ប្រព័ន្ធអនុគ្រោះ(EBA)បានរួមចំណែកដល់ការងារ និងកំណើននៅក្នុងវិស័យវាយនភ័ណ្ឌ ដែលមានចំនួន៧៥%នៃការនាំចេញរបស់កម្ពុជាទៅសហភាពអឺរ៉ុប។ សហភាពអឺរ៉ុបគឺជាទីផ្សារសំលៀកបំពាក់ធំបំផុតរបស់កម្ពុជា ដែលរួមចំណែក៤៦%នៃការនាំចេញសម្លៀកបំពាក់។ សហរដ្ឋអាមេរិក បានរួមចំណែកប្រមាណជាពាក់កណ្តាលនៃតួរលេខនេះ (គឺប្រហែល ២៤%)។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### អាមេរិកផ្អាកជាបណ្តោះអាសន្នលើការយកពន្ធនាំចូលរថយន្តដែលលោកត្រាំបានដាក់

មន្ត្រីពាណិជ្ជកម្មជាន់ខ្ពស់របស់អាមេរិកបានមានប្រសាសន៍ថា ពួកគេនឹងផ្អាកបណ្តោះអាសន្នលើការយកពន្ធថ្មីរបស់លោក ត្រាំ លើការនាំចូលយានយន្តគ្រប់ប្រភេទ ដែលបានដាក់បន្ថែមលើថ្លៃដើមរហូតដល់២៥% ទៅលើយានយន្តដែលផលិតនៅបរទេស ដែលបន្ថែមដល់ទៅ ២ ២៧០ ដុល្លារអាមេរិកទៅលើថ្លៃដើមនៃរថយន្តផលិតនៅអាមេរិក និង ៦ ៨៧៥ដុល្លារអាមេរិកទៅលើរថយន្តធម្មតា និងរថយន្តដឹកទំនិញដែលនាំចូល។

ពន្ធនាំចូលត្រូវបានកែតម្រូវដោយផ្អែកទៅលើបញ្ហាសន្តិសុខជាតិ ជាមធ្យោបាយមួយក្នុងការគេចចេញពីច្បាប់របស់អង្គការពាណិជ្ជកម្ម។ មន្ត្រីនឹងរង់ចាំលទ្ធផលនៃរបាយការណ៍របស់នាយកដ្ឋានពាណិជ្ជកម្មស្តីពី ផលប៉ះពាល់ផ្នែកសុវត្ថិភាពនៃការនាំចូលរថយន្ត។ របាយការណ៍នេះ នឹងពិនិត្យមើល

លើរថយន្តច្រើនប្រភេទ រួមមានរថយន្តស្ព័រ (sport utility vehicle) រថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនស្រាល ព្រមទាំងគ្រឿងបន្លាស់រថយន្ត។

ក្រុមហ៊ុន និងរដ្ឋាភិបាលតាំងពីទ្វីបអឺរ៉ុបនិងទ្វីបអាស៊ីបានព្រមានលោកត្រាំថា ពន្ធគយនេះនឹងប៉ះពាល់ដល់សេដ្ឋកិច្ចអាមេរិក និងបង្អាក់ដល់ឧស្សាហកម្មរថយន្តពិភពលោក។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាអតិផរណា នៅប្រទេសម៉ាឡេស៊ី សិង្ហបុរី ជប៉ុន និងហុងកុង និងផលិតផលក្នុងស្រុកសរុបនៅប្រទេសថៃ។

ខាងក្រោមនេះគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍដែលក្រុមFACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី១៩ ខែវិច្ឆិកា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែតុលា
- កំណើនផ.ស.ស.របស់ប្រទេសថៃ សម្រាប់ត្រីមាសទី៣ ក្នុងឆ្នាំ២០១៨
- កំណើនប្រាក់កម្ចីរបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែតុលា
- គណនីចរន្តនៃតំបន់អឺរ៉ុប សម្រាប់ខែកញ្ញា

<u>ថ្ងៃអង្គារ ទី២០ ខែវិច្ឆិកា</u>

- ភាពគ្មានការងារធ្វើរបស់ប្រទេសបារាំងសម្រាប់ ត្រីមាសទី៣ ក្នុងឆ្នាំ២០១៨
- គណនីចរន្តរបស់តៃវ៉ាន់សម្រាប់ត្រីមាសទី៣ក្នុងឆ្នាំ២០១៨
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែតុលា
- សន្ទស្សន៍តម្លៃរបស់អ្នកផលិតនៅកូរ៉េខាងត្បូង សម្រាប់ខែតុលា
- ការចាប់ផ្តើមលំនៅស្ថានរបស់សហរដ្ឋអាមេរិច នៅខែតុលា

<u>ថ្ងៃពុធ ទី២១ ខែវិច្ឆិកា</u>

- ទិន្នន័យការលក់ដុំនៅប្រទេសកាណាដា សម្រាប់ខែកញ្ញា
- សន្ទស្សន៍សកម្មភាពឧស្សាហកម្មទាំងអស់របស់ប្រទេសជប៉ុន សម្រាប់ខែកញ្ញា
- ការបញ្ជាទិញទំនិញប្រើប្រាស់របស់អាមេរិច សម្រាប់ខែតុលា

<u>ថ្ងៃព្រហស្បតិ៍ ទី២២ ខែវិច្ឆិកា</u>

- អត្រាអតិផរណារបស់ប្រទេសជប៉ុន សម្រាប់ខែតុលា
- ផ.ស.ស. របស់សិង្ហបុរីសម្រាប់ត្រីមាសទី៣ក្នុងឆ្នាំ២០១៨
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់ខែតុលា
- អត្រាភាពគ្មានការងារធ្វើនៅតៃវ៉ាន់ សម្រាប់ខែតុលា

<u>ថ្ងៃសុក្រ ទី ២៣ ខែ វិច្ឆិកា</u>

- អត្រាអតិផរណារបស់ប្រទេសកាណាដា សម្រាប់ខែតុលា
- អត្រាអតិផរណារបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែតុលា
- អត្រាអតិផរណារបស់សិង្ហបុរី គិតត្រឹមខែតុលា
- អត្រានៃការលក់រថយន្តថ្មីរបស់ប្រទេសថៃ សម្រាប់ខែតុលា